ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**************

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៨៦៩ / ០២.១១.២០១០
សាលដីកា
លេខ: ៨៥ ក្រ.III.ស/២៦.១០.២០១២

# គោរនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៨៦៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] ប្រុស ហៅ វ៉េង ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ មុខរបរៈស៊ីឈ្នួលមើលមាន់ កំរិតវប្បធម៌ថ្នាក់ទី៩ កើតនៅភូមិស្តុកធ្លក ឃុំទទង់ ស្រុកដងទង់ ខេត្តកំពត ទីលំនៅមុនចាប់ខ្លួនភូមិអូរដាលើ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន។

មេធាវីការពារលោកស្រី [redacted] ម៉េងអ៊ាម។

<u>ជាប់ចោទពីបទ:</u> ចែកចាយគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅ ភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ៦ដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ វេលាម៉ោង១ និង០០នាទី មានករណីចែកចាយគ្រឿងញៀនមួយបង្កឡើងដោយឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ៤០ឆ្នាំ បានទិញថ្នាំញៀន១៥គ្រាប់ ហើយបានជក់១គ្រាប់ និងសល់ ១៤គ្រាប់ ទៀត ទុកចែកចាយឲ្យអ្នកផ្សេងៗ នៅចំណុចភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០២ «ក» ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១- កែប្រែបទចោទប្រកាន់ពីបទ ចែកចាយគ្រឿងញៀនខុសច្បាប់ តាមបញ្ញត្តិមាត្រា ៣៦ ថ្មី មកជាប្រើប្រាស់គ្រឿងញៀនខុសច្បាប់ តាមបញ្ញត្តិមាត្រា ៩៨ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២- ផ្ដន្ទាទោសលើឈ្មោះ [redacted] ប្រុស ភេទប្រុស អាយុ៤០ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់មួយខែ គិតចាប់ពីថ្ងៃឃាត់ខ្លួន ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០។

ពីបទ: ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា ៩៨ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣- វត្ថុតាងរួមមាន: ថ្នាំញៀនចំនួន ១៤គ្រាប់ ត្រូវរឹបអូសបំផ្លាញចោល។

៤- សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់លោក [redacted] ព្រះរាជអាជ្ញារងសាលាដំបូងខេត្តបាត់ដំបង ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០២ «ក» ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តបាត់ដំបង គ្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] ប្រុស ឆ្លើយសារភាពទទួលស្គាល់នូវសកម្មភាពរបស់ខ្លួនថា កាលពី ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ខ្លួនពិតជាបានពឹងពាក់អ្នកម៉ូតូឌុបឲ្យទិញថ្នាំញៀនប្រភេទយ៉ាម៉ាចំនួន ១៥គ្រាប់ អស់ប្រាក់ចំនួន ១៦០០បាត យកមកជក់ និងលក់ចែកចាយបន្តទៀត។ ខ្លួនទិញថ្នាំយ៉ាម៉ាក្នុងមួយគ្រាប់ថ្លៃ ១០០បាត ៗ

លក់វិញ១២០បាត។ ការប្រព្រឹត្តបែបនេះ ដោយសារខ្លួនធ្លាប់ជក់ ជាយូរខែមកហើយ។ សំណូមពរ សុំបន្ធូរបន្ថយទោសដល់រូបខ្លួន។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ជនជាប់ចោទគាត់បានឆ្លើយពង្វៀង តែចុងក្រោយគាត់បានឆ្លើយសារភាពថា គាត់ពិតជាប្រព្រឹត្តដូចការចោទប្រកាន់របស់អយ្យការអមសាលាដំបូង មែន សុំក្រុមប្រឹក្សា ពិចារណា និងសម្រេចទៅតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

សាលាដំបូងបានសម្រេចកែប្រែបទចោទពីបទ ចែកចាយគ្រឿងញៀនខុសច្បាប់ តាមមាត្រា ៣៦ ថ្មី មកជា ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ តាមមាត្រា ៩៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិញ ហើយពេលនេះជនជាប់ចោទបានសារភាព ដោយមានភាពស្មោះត្រង់ ហើយគ្រឿងញៀនមានចំនួនតិចត្រឹមតែជាងដប់គ្រាប់ប៉ុណ្ណោះ សូមក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ប្រុស,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. នៅសវនាការសាលាឧទ្ធរណ៍នេះ ជនជាប់ចោទ បានឆ្លើយសារភាពដោយទទួលស្គាល់នូវសកម្មភាពរបស់ខ្លួនថា កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ខ្លួនពិតជាបានពឹងពាក់អ្នកម៉ូតូឌុបឲ្យទិញថ្នាំញៀនប្រភេទយ៉ាម៉ាចំនួន១៥គ្រាប់ អស់ប្រាក់ចំនួន ១៦០០បាត យកមកជក់ និងលក់ចែកចាយបន្តទៀត។ ខ្លួនទិញថ្នាំយ៉ាម៉ាក្នុងមួយគ្រាប់ថ្លៃ១០០បាត លក់វិញ១២០បាត។ ការប្រព្រឹត្តបែបនេះ ដោយសារខ្លួនធ្លាប់ជក់ជាយូរខែមកហើយ ខានមិនបានទេ។

៣. មានពិរុទ្ធលើជនជាប់ចោទ ពីបទ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤. សាលក្រមព្រហ្មទណ្ឌលេខ ១០២ «ក» ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តបាត់ដំបង សម្រេចមានលក្ខណៈខុសឆ្គង ត្រង់ចំណុចទី១ និងទី២ គួបដិសេធចោល ហើយសម្រេចឡើងវិញ ក្រៅពីនេះ គួរទុកនៅដដែល។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២. បដិសេធចោលជាអសារបង់ នូវចំណុចទី១ និងទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ ១០២ «ក» ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តបាត់ដំបង ហើយសម្រេចឡើងវិញ:

ក. កែប្រែបទចោទ ពីមាត្រា ៣៦ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជាមាត្រា ៣៣ ថ្មី កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ផ្តន្ទាទោសលើឈ្មោះ [redacted] ប្រុស ហៅ វ៉ែង ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំគិតពីថ្ងៃឃុំខ្លួន ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ពីបទ ជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅ ភូមិអូរដាលើ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី កថាខណ្ឌ ទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ក្រៅពីនេះទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ, បើកផ្លូវតវ៉ាតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី 04 ខែ 6 ឆ្នាំ ២០១៤

ក្រឡាបញ្ជី